# រឿង ស្លូភាព និង ផ្គរឈាន់



pSayecjB Tcatkarkckar Krekass I    RksgGbrCat



នៅក្នុងភូមិមួយឆ្ងាយពីទីក្រុង មានកុមារីពីរនាក់ នៅផ្ទះជិតគ្នា ម្នាក់ឈ្មោះសូភាព ម្នាក់ឈ្មោះផានី ។

សូភាពជាក្មេងស្លូត ហើយឧស្សាហ៍ណាស់។ រាល់ព្រឹកនាងក្រោកពីព្រលឹមមិនបាច់ម្ដាយដាស់ទេ ។ នាងរៀបចំកន្លែងដេករបស់នាងយ៉ាងស្អាត រួចទើបទៅលុបមុខ ដុសធ្មេញសិតសក់និងផ្លាស់សម្លៀកបំពាក់ពេលយប់ចេញ។ មិនតែប៉ុណ្ណោះ សូភាពជួយបោសសំអាតផ្ទះថែមទៀត។



ផានីជាក្មេងខ្ជិល ។
វាដេកទាល់ថ្ងៃរះក៏មិនទាន់ក្រោកផង ។
រាល់ព្រឹកគេឮតែមាត់ម្តាយថា :
« ផានី! ក្រោកឡើង ថ្ងៃរះខ្ពស់ហើយ! ផានី! នៅអង្គុយសំកុកដល់ណាទៀតម្តេចមិនទៅលុបមុខមាត់? យី ! ឯងនេះខ្ជិលជាង "អាតី" ទៅទៀត » ។





ផានីកាចណាស់ ។ វាតែងតែបង្ករឿងជម្លោះនឹងក្មេងៗ ឯទៀតគ្រប់ទីកន្លែង ។ ហេតុនេះហើយ ទើបបានគេឱ្យងារថា : "**ផ្គរលាន់**" ។

ថ្ងៃមួយ សូភាពនិងផ្គរលាន់បានបបួលគ្នាទៅបេះផ្លែឈើក្នុងព្រៃ ។ តាមផ្លូវកុមារីទាំងពីរបានជួបនឹងដូនចាស់ពិការម្នាក់ ដើរដោយពិបាក ។ ឃើញហើយ ផ្គរលាន់ពោលថា : « យី! យាយនេះដើរទើមៗ ដូច្នេះ អ្នកណាដើរតាមក្រោយបាន » ។ ថាហើយវាដើរបញ្ជិតយាយចាស់រឹងទៅ ។ ដោយពិការស្រាប់ យាយចាស់ក៏ដួលច្រងាប់ច្រងិល ទៅលើចិញ្ចើមផ្លូវ ។







សូភាពឃើញដូច្នោះ ក៏ស្ទុះទៅលើកដូនចាស់ឡើង ។ នាងបោសដីដែលប្រឡាក់លើសម្លៀកបំពាក់រហែករបស់យាយ ហើយកាច់មែកឈើមួយជូនទៅដូនចាស់ធ្វើជាឈើច្រត់ ។

ដូនចាស់និយាយទៅកាន់សូភាពថា : « ចៅជាក្មេងមានចិត្តល្អណាស់ មិនដូចចៅនុ៎ះ ! គ្មានចេះអាណិតចំពោះចាស់ទុំសោះ » ។

សូភាពពោលដោយស្ដាយថា : « មិនគួរផានីធ្វើឱ្យយាយដួលដូច្នេះសោះ ! » ។

មុននឹងបែកពីសូភាព ដូនចាស់ឱ្យពរថា : « សូមឱ្យចៅបានសេចក្ដីសុខគ្រប់ប្រការ » ។

សូភាពទទួលថា « សាធុ ! សាធុ ! » ។





លុះដើរទៅមុខទៀត សូភាពនិងផ្គរលាន់ បានឃើញសំបុកចាបមួយធ្លាក់មកដី ។ ក្នុងសំបុកចាបនោះ មានកូនចាបពីរទើបនឹងញាស់ យំ ចេប ! ចេប ! ។

ផ្គរលាន់ឃើញហើយត្រេកអរណាស់ វាស្រែកថា : « អៃយ៉ា ! សំបុកចាបនេះល្អណាស់តើ ! អញរើសវាយកទៅធ្វើកន្ត្រកលេង » ។

នៅលើមែកឈើ មេចាបស្រែកយំ លោតចុះ លោតឡើង ភិតភ័យនឹងមនុស្សរើសយកសំបុកនិងកូនខ្លួន ។





សូភាពឃើញដូច្នោះ នឹកអាណិតចាបជាខ្លាំង ។ វាក៏និយាយទៅកាន់ផ្គរលាន់ថា : « ផានី ! យកសំបុកចាបនេះទៅទុកឱ្យមេវាវិញទៅ ។ ឯងឃើញទេ មេវាកំពុងស្រែកយំឯណោះ » ។

ផ្គរលាន់ពេបមាត់តបថា : « កុំគ្រាន់បើពេក ! របស់យើងរើសបានស្រេចតែយើង » ។

កូនចាបនិងមេ ស្រែកកាន់តែខ្លាំងឡើង ។ សូភាពមិនដឹងធ្វើដូចម្ដេច ក៏និយាយម្ដងទៀតថា : « ផានី ! ឯងដូរសំបុកចាបនេះឱ្យយើងមក យើងឱ្យបាយនិងម្ហូបរបស់យើងទៅឯងពាក់កណ្ដាល » ។

ផ្គរលាន់គិតបន្តិចក៏យល់ព្រម ។ សូភាពអរណាស់ ។ វាម្នីម្នាឡើងដើមឈើយកសំបុកចាបទុកឱ្យមេវាវិញ ។





កុមារីទាំងពីរក៏បន្តដំណើរទៅទៀត ។ ពេលនោះ ផ្គរលាន់ក្រឡេកឃើញកូនស្វាមួយជាប់អន្ទាក់ ។ វាក៏ស្រែកថា : « អៃយ៉ា ! អានេះជាប់អន្ទាក់ទេតើ ! អញនឹងដោះយកអាឯងទៅលក់ម្ដង » ។

សូភាពនឹកអាណិតសត្វនេះពេក ក៏អង្វរផ្គរលាន់ថា : « ផានី ! លែងកូនស្វានេះវិញទៅ កុំឱ្យវាព្រាត់ប្រាសមេបាវា » ។

ផ្គរលាន់សម្លក់សូភាពហើយតបថា : « ឯងឱ្យយើងលែងងាយៗ ដូច្នេះ មិនបានទេ » ។

សូភាពយល់ចិត្តផ្គរលាន់ក៏និយាយថា : « ឯងលែងកូនស្វានេះចុះ យើងនឹងចែកផ្លែឈើដែលយើងបេះបាន ឱ្យឯងឱ្យពាក់កណ្ដាល » ។

ផ្គរលាន់ញញឹមយល់ព្រម ។





សូភាពបេះបានផ្លែឈើទុំល្អៗ ជាច្រើន ។ ផ្គរលាន់ច្រណែន ទើបរកឧបាយកល យកផ្លែឈើរបស់សូភាពអស់ ។ សូភាពយំបណ្ដើរ ដើរបណ្ដើរ ទៅជួបស្វាដែលនាងជួយពីថ្ងៃមុន ។ ស្វាបានបបួលគ្រួសារស្វា បេះផ្លែឈើឱ្យសូភាពយ៉ាងច្រើន ។ ឯចាបក៏យកសំបុកពីរមកឱ្យសូភាពដាក់ផ្លែឈើនោះដែរ ។





សូភាពដើរវង្វេងផ្លូវ ។ នាងមើលទៅឃើញភ្លើងផ្លុង ៗ ឯនាយ ក៏ខំស្រូតតម្រង់ទៅដល់ខ្ទមទ្រុឌទ្រោមមួយ ។ សូភាពគោះទ្វារ ប៉ូក! ប៉ូក! ។ ទ្វាររបើកឡើង លេចដូនចាស់ពិការដែលសូភាពជួយពីថ្ងៃមុន ។ នាងនិយាយឡើងថា ៖ « ជម្រាបសួរយាយ ! » ។

ដូនចាស់ញញឹមតបថា ៖ « អូ! អាយុវែងចៅ! ចៅទៅណាទាំងយប់ដូច្នេះ ? » ។

សូភាពនិយាយរឿងរបស់ខ្លួនប្រាប់ដូនចាស់សព្វគ្រប់ ។

ដូនចាស់និយាយទៅកាន់សូភាពថា ៖ « សូមចៅស្នាក់នៅទីនេះហើយ ព្រឹកឡើងសឹមយាយបង្ហាញផ្លូវទៅផ្ទះវិញ » ។





ដូនចាស់ជាតួទេពធីតារក្សាព្រៃ ។ ដោយយល់ថាសូភាពជាក្មេងចិត្តល្អ ស្លូត ជួយអ្នកមានទុក្ខ យប់នោះ ដូនចាស់ក៏ធ្វើឱ្យផ្លែឈើរបស់សូភាពទាំងអស់ក្លាយទៅជាមាស។ សូភាពភ្ញាក់ឡើងត្រេកអរជាខ្លាំងហើយសូមលាដូនចាស់ត្រឡប់ទៅផ្ទះវិញ។





ចំណែកផ្គរលាន់ កាលបើបានដំណឹងនេះហើយ មានសេចក្ដីលោភចង់បាន។ ថ្ងៃមួយនាងចូលទៅក្នុងព្រៃ បេះផ្លែឈើបានហើយ ក៏តាំងដើររកលំនៅជូនចាស់ទេពធីតា។

ចាបបានឃើញផ្គរលាន់មុនគេ ហើរទៅឱ្យដំណឹងស្វា។ ស្វានាំគ្រួសារស្វាទាំងតូចទាំងធំ មកបន្ទោបង់ដាក់លើផ្គរលាន់ ដើម្បីសងសឹក។





ផ្គរលាន់រត់ទៅទៀត ក៏ស្រាប់តែដល់ផ្ទះដូនចាស់។ វាអរណាស់ ខំគោះទ្វារ ប៉ូក! ប៉ូក!។ ទ្វាររបើកឡើង។ ផ្គរលាន់ស្គាល់ច្បាស់ជាដូនចាស់ដែលនាងបាន ដើរបំប៉ះ ឱ្យដួលពីថ្ងៃមុន។ វាពោលថា : « នែ យាយ! យាយឯងនេះឬ ដែល ចេះធ្វើឱ្យផ្លែឈើក្លាយទៅជាមាសនោះ ? » ។

ដូនចាស់ញញឹមហើយតបថា : « ពិតប្រាកដហើយចៅ! ចុះចៅមានបំណងយ៉ាង ណាដែរ ? » ។

ផ្គរលាន់ឆ្លើយដោយគ្មានការគួរសមថា : « ខ្ញុំចង់ឱ្យយាយឯង ធ្វើផ្លែឈើទាំងនេះ ឱ្យក្លាយទៅជាមាសដូចរបស់សូភាព » ។





ដូនចាស់សំឡឹងមុខផ្គរលាន់យ៉ាងយូរ រួចនិយាយមួយៗ ថា : « ឱចៅអើយ! ចៅចង់ឱ្យបានដូចសូភាព។ សូភាពមានចិត្តល្អចេះអាណិតមនុស្សសត្វដែលមានទុក្ខ ជួយយកអាសាអ្នកដទៃ គោរពចាស់ទុំ។ អំពើល្អទាំងនោះ អាចផ្សំនឹងឥទ្ធិឫទ្ធិយាយ ធ្វើឱ្យផ្លែឈើសូភាពក្លាយទៅជាមាសបាន។ ចំណែកអំពើរបស់ចៅ មិនដឹងតើធ្វើបាន ដូចសូភាព ឬ មិនបានទេ » ។





ផ្គរលាន់អេះអុញបន្តិច តែដោយសេចក្តីលោភ ក៏បង្ខំទៅដូនចាស់ថា : « ធ្វើឱ្យ
ឆាប់ឡើង! ធ្វើឱ្យឆាប់ឡើង! » ។

ជាបន្ទាន់នោះ ដូនចាស់លើកដៃឡើងចង្អុលផ្លែឈើរបស់ផ្គរលាន់ ។ រំពេចនោះ ស្រាប់តែផ្លែឈើក្លាយទៅពស់អស់គ្មានសល់ ។ ផ្គរលាន់ភ័យណាស់ ទម្លាក់កន្ត្រកផ្លែឈើចោលទៅដី ស្រែកភ្លាត់សំឡេងរួចដួលព្រួសនៅចំពោះមុខទេពធីតារក្សាព្រៃ ។





ម្ដាយឪពុកផ្គរលាន់ ដោយបាត់កូនក៏ដើររក ហើយទៅឃើញកូនដួលដេកមិនដឹងខ្លួននៅក្នុងព្រៃ ក្រោយផ្ទះ ។

ពេលផ្គរលាន់ដឹងខ្លួនវិញ វាយកដៃបិទភ្នែក ស្រែកថា : « ពស់! ពស់! ពស់ច្រើនណាស់! » ។

ប៉ុន្តែលុះវាបើកភ្នែកឡើង ស្រាប់តែឃើញម្ដាយវាឈ្ងោកមុខមកជិតវា ហើយនិយាយដោយពាក្យផ្អែមល្ហែមថា : «ឥតមានពស់ទេកូន ! ម្ដាយនៅជិតនេះហើយកុំភ័យ! » ។





ផ្គរលាន់ មានជំងឺជាខ្លាំង ដោយសារតែភ័យជ្រុលពេក។

យប់មួយ ទេពធីតារក្សាព្រៃ បានពន្យល់សប្តិវាថា : « បើឯងកាន់ចិត្តល្អ គោរពឪពុកម្តាយនិងចាស់ទុំ កុំខិលច្រអូស ស្លូតបូត នោះយើងអាចជួយឯងឱ្យជាបាន។ ប៉ុន្តែ បើឯងនៅព្រហើនកោងកាចដាក់ចាស់ទុំ មិនស្តាប់បង្គាប់ឪពុកម្តាយ នោះយើងពុំអាចជួយឯងបានឡើយ »។







ភ្ញាក់ឡើង ផ្គរលាន់ខំតាំងចិត្តកែខ្លួនឱ្យបានល្អដូចសូភាព ។ មិនយូរប៉ុន្មានជំងឺនាងក៏បានជាស្រឡះ ។

ផ្គរលាន់ក្លាយទៅជាក្មេងល្អម្នាក់ ជាទីពេញចិត្តនៃចាស់ទុំនិងមិត្តភ័ក្តិ ។ អ្នកទាំងពួងក៏លែងហៅនាងថា : "**ផ្គរលាន់**"ទៀតដែរ ។





អ្នកនិពន្ធ
អ្នកស្រី អុី.តាវ យ៉េ
វិចិត្រករ
រស់ កន
ជូន សម្បត្តិ

# សុភាព និង ផ្គរលាន់

ទីប្រឹក្សា
ជុន ហ៊ាន- ហូ តុង ហូ
គណៈកម្មការពិនិត្យ
សរ-សារុន.................ប្រធាន
តាន់-អុឹម...................សមាជិក
ប៉ក់ សាម័យ-ម៉ង់សាណា..........
នូវ-ផុន តុន..........................
សេក-ចៀវ ស៊ុម....................
ហួរ-ហេង............................


This book was reprinted by Caring for Young Khmer with the financial assistance of Ms. Nobuko ASAI

| | | |
|---|---|---|
| បោះពុម្ពឡើងវិញដោយ | : អង្គការគាំពារកុមារខ្មែរ (CYK)<br>នៅភ្នំពេញ ខែកក្កដា ឆ្នាំ២០១០ | 増刷：特定非営利活動法人　幼い難民を考える会<br>2010 年 7 月　プノンペン |
| មូលនិធិ | : លោកស្រី អាសាយ ណូប៊ុកុ | 協力：浅井　信子 |
| ចំនួន | : ៣០០ក្បាល | 部数：300 冊 |
| លេខ | : CYK N10026 | 番号：CYK N10026 |
| រោងពុម្ព | : JSRC Printing House | 印刷所：JSRC Printing House |